# អតិថិជន អ អេច ប៊ី ព្រេមៀ

១.  ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក (ក្រុមហ៊ុនចុះបញ្ជីក្រោមលេខ ០០០០១៨១២) នឹងត្រូវបានហៅថា “អ អេច ប៊ី”។

## កាលកំណត់ និងលក្ខខណ្ឌផ្សេងៗរបស់អតិថិជន អ អេច ប៊ី ព្រេមៀ

រាល់អតិថិជន អ អេច ប៊ី ព្រេមៀ ទាំងអស់ត្រូវអនុវត្តតាមកាលកំណត់ និងលក្ខខណ្ឌដូចមានចែងនេះ។ នៅក្នុងកាលកំណត់ និងលក្ខខណ្ឌទាំងនេះ "អតិថិជន អ អេច ប៊ី ព្រេមៀ គឺសំដៅលើអតិថិជនរបស់ធនាគារតែម្នាក់ ឬជាក្រុម អតិថិជនពីរនាក់ ឬច្រើននាក់ ដែលបានធ្វើការស្នើសុំជាអតិថិជន អ អេច ប៊ី ព្រេមៀ ហើយនឹងអ្នកដែលត្រូវបានធនាគារព្រមទទួលយកធ្វើជាអតិថិជន អ អេច ប៊ី ព្រេមៀ"។

ឯកសិទ្ធិ និងសេវាកម្មរបស់អតិថិជន អ អេច ប៊ី ព្រេមៀ ត្រូវបានគ្រប់គ្រងដោយកាលកំណត់ និងលក្ខខណ្ឌផ្សេងៗ ដែលអនុវត្តចំពោះការផ្តល់សេវាកម្មនីមួយៗ។

ឯកសិទ្ធិ និងសេវាកម្មរបស់អតិថិជន អ អេច ប៊ី ព្រេមៀ ត្រូវបានគោរពផងដែរ តាមរយៈកាលកំណត់ និងលក្ខខណ្ឌផ្សេងៗ ដូចបានបញ្ជាក់នៅក្នុង "កាលកំណត់ និងលក្ខខណ្ឌ សម្រាប់គណនី និងសេវាកម្មពាក់ព័ន្ធដទៃទៀត (សម្រាប់រូបវន្តបុគ្គល)" (អតិថិជន អ អេច ប៊ី ព្រេមៀ ជាក្រុម "កាលកំណត់ និងលក្ខខណ្ឌ សម្រាប់គណនី")។ សម្រាប់សេវាកម្មធនាគារជាកញ្ចប់ នៅក្នុងករណីមានភាពផ្ទុយគ្នារវាង កាលកំណត់ និងលក្ខខណ្ឌអតិថិជន អ អេច ប៊ី ព្រេមៀ និង "កាលកំណត់ និងលក្ខខណ្ឌសម្រាប់គណនី" នោះកាលកំណត់ និងលក្ខខណ្ឌអតិថិជន អ អេច ប៊ី ព្រេមៀត្រូវកំណត់យកជាគោល។

### ១. អតិថិជន អ អេច ប៊ី ព្រេមៀ

ក. អតិថិជន អ អេច ប៊ី ព្រេមៀ គឺជាកម្មវត្ថុនៃការត្រួតពិនិត្យប្រចាំខែតាមការសម្រេចរបស់ធនាគារ។

### ២. ការរំលាយកិច្ចព្រមព្រៀងនៃអតិថិជន អ អេច ប៊ី ព្រេមៀ

ក. អតិថិជន អ អេច ប៊ី ព្រេមៀ ឬក្នុងករណី អតិថិជន អ អេច ប៊ី ព្រេមៀរួមគ្នា មានតែមួយរូបក្នុងចំណោមទាំងអស់គ្នាក៏អាចធ្វើការរំលាយកិច្ចព្រមព្រៀង អតិថិជន អ អេច ប៊ី ព្រេមៀនេះបានដែរ ដោយត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារ។

ខ. រាល់ឯកសិទ្ធិរបស់អតិថិជន អ អេច ប៊ី ព្រេមៀបានស្រុះស្រួលឲ្យអតិថិជន អ អេច ប៊ី ព្រេមៀ អាចត្រូវបានរំលាយបានភ្លាមៗនៅពេលដែល គាត់/នាងបានស្លាប់ ឬក្ស័យធន។ ក្នុងករណីអតិថិជន អ អេច ប៊ី ព្រេមៀរួមគ្នា ធនាគារអាចធ្វើការសម្រេចចិត្តរំលាយ ឬបន្តយោងទៅលើឯកសិទ្ធិដើម្បីសង្គ្រោះអតិថិជន អ អេច ប៊ី ព្រេមៀ។

គ. ចំពោះអតិថិជន អ អេច ប៊ី ព្រេមៀ ដែលក្លាយជាអតិថិជន អ អេច ប៊ី ព្រេមៀ ដោយការសម្រេច និងយោងតាមគោលការណ៍របស់ធនាគារ ។ ធនាគារអាចធ្វើការលុបសិទ្ធិជាអតិថិជន អ អេច ប៊ី ព្រេមៀ បានគ្រប់ពេលវេលាទៅកាន់អតិថិជន អ អេច ប៊ី ព្រេមៀ ដោយពុំចាំបាច់ធ្វើការជូនដំណឹង ឬបញ្ជាក់ហេតុផលអ្វីឡើយ។

### ៣. ការផ្លាស់ប្តូរអាសយដ្ឋាន

ក. អតិថិជន អ អេច ប៊ី ព្រេមៀ ត្រូវជូនដំណឹងជាបន្ទាន់មកកាន់ធនាគារនៅពេល គាត់/នាង/ពួកគេ មានការផ្លាស់ប្តូរអាសយដ្ឋាន។

ខ. លើសពីនេះ អតិថិជន អ អេច ប៊ី ព្រេមៀ ត្រូវជូនដំណឹងជាបន្ទាន់មកកាន់ធនាគារនៅពេល គាត់/នាង/ពួកគេ មានការផ្លាស់ប្តូរការងារ និង/ឬអាសយដ្ឋានកន្លែងធ្វើការ។

### ៤. សំណង

ក. អតិថិជន អ អេច ប៊ី ព្រេមៀ ត្រូវសងសំណងយ៉ាងពេញលេញទៅធនាគាររាល់ការចំណាយផ្សេងៗ (បូករួមទាំងសេវាផ្នែកច្បាប់ ដែលជាសំណងគ្រឹះ) កើតឡើងដោយធនាគារស្របតាមកាលកំណត់ និងលក្ខខណ្ឌនេះ និងរាល់ការរកឃើញចំណាយផ្សេងទៀតលើធនាគារ ឬកើតឡើងដោយធនាគារមានដំណើរការនីតិវិធីច្បាប់ ផ្សេងៗ។ ករណីអតិថិជន អ អេច ប៊ី ព្រេមៀ ដែលមានសមាជិក ពីរនាក់ ឬច្រើននាក់ ពួកគេត្រូវទទួលខុសត្រូវរួមគ្នា និងទទួលខុសត្រូវចំពោះការទទួលខុសត្រូវណាមួយដែលកើតមានដូចមានចែងខាងលើ។

### ៥. ការលះបង់សិទ្ធិ

ក. គ្មានការពន្យាពេលក្នុងការអនុវត្តសិទ្ធិ ការធ្វេសប្រហែស ឬការលះបង់សិទ្ធិដោយធនាគារនៅក្នុងការអនុវត្តលើកាលកំណត់ និងលក្ខខណ្ឌ ដូចមានចែងនេះ ហើយនឹងធ្វើការវិនិច្ឆ័យលើសិទ្ធិរបស់ធនាគារ ដែលត្រូវអនុវត្តយ៉ាងតឹងរ៉ឹងដើម្បីសុវត្ថិភាព។

**៦. ការធ្វើវិសោធនកម្មលើកាលកំណត់ និងលក្ខខណ្ឌ**

ក. ធនាគារអាចមានសិទ្ធិសម្រេចក្នុងការធ្វើវិសោធនកម្ម បន្ថែម ឬលុបចោល លើកាលកំណត់ និងលក្ខខណ្ឌដូចមានចែង ដោយគ្មានការជូនដំណឹងទៅកាន់អតិថិជន អ អេច ប៊ី ព្រមៀជាមុននោះទេ។

**៧. ច្បាប់គ្រប់គ្រង**

ក. កាលកំណត់ និងលក្ខខណ្ឌដូចមានចែងនេះ ត្រូវគ្រប់គ្រង និងបកស្រាយដោយអនុលោមតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។